CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

សាកលវិទ្យាល័យស៊ីដនី

សង្ខេបសម្រាប់
គោលនយោបាយ

ឆ្នាំ ២០១១ លេខ ១១

# ការសិក្សាតម្រូវការទឹកស្រោចស្រព សម្រាប់គាំទ្រ ដល់ការគ្រប់គ្រងធារាសាស្ត្រក្នុងអាងស្ទឹង ប្រទេសកម្ពុជា[១]

*ដោយ ចែម ផល្លា*[២] Philip Hirsch[៣] *និងសុមេធ ប៉ារ៉ាឌី*[៤]

ការសិក្សានេះ ស្វែងរកលទ្ធភាពជួយលើកកម្ពស់ការគ្រប់គ្រងធារាសាស្ត្រក្នុងអាងស្ទឹង តាមរយៈការសិក្សាជលសាស្ត្រ ដោយប្រើម៉ូដែល WEAP។ ការសិក្សានេះបង្ហាញនូវជម្រើសច្បាស់លាស់ ដល់អ្នកបង្កើតគោលនយោបាយ និងអ្នកពាក់ព័ន្ធស្តីពីការគ្រប់គ្រងតម្រូវការទឹកស្រោចស្រព។ អត្ថបទនេះ ផ្អែកលើបទពិសោធន៍បានមកពីការសិក្សាក្នុងអាងស្ទឹងជ្រៃបាក់ ខេត្តកំពង់ឆ្នាំង។

## ខ្លឹមសារសង្ខេបសំខាន់ៗ

- កំណើនចំនួនប្រជាជន នាំឲ្យមានកំណើនតម្រូវការម្ហូបអាហារ។ ប្រជាជននៅជុំវិញបឹងទន្លេសាប បានបង្កើនដំណាំស្រូវពីការធ្វើស្រែតែមួយដងក្នុងរដូវវស្សា ទៅធ្វើពីរឬបីដងក្នុងមួយឆ្នាំ ហើយតម្រូវការទឹកស្រោចស្រពក៏កើនឡើងតាមនោះដែរ។
- កំណើនផ្ទៃដីស្រោចស្រព បង្កើនការប្រជែងគ្នាប្រើប្រាស់ទឹក ដែលនាំឲ្យមានកង្វល់ពីបញ្ហាសមធម៌សង្គម និងការថែទាំបរិស្ថាន។
- ដំណើរការកែទម្រង់គោលនយោបាយ រាប់ទាំងគោលនយោបាយគ្រប់គ្រងអាងទន្លេផង បាននិងកំពុងនាំមកនូវដំណោះស្រាយដ៏សមស្របដើម្បីឆ្លើយតបចំពោះកង្វល់ទាំងនោះ។ ប៉ុន្តែត្រូវមានវិធីសាស្ត្រល្អៗច្រើនថែមទៀត ដើម្បីជាត្រីវិស័យសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត។
- ការគ្រប់គ្រងតាមទម្លាប់ចាស់ ដែលផ្តោតខ្លាំងតែទៅលើសក្តានុពលទឹកក្នុងអាងស្ទឹង មិនសមស្របក្នុងបរិបទបច្ចុប្បន្នទេ ដូច្នេះត្រូវពិចារណាពីជម្រើសផ្សេងៗទៀត ក្នុងការគ្រប់គ្រងតម្រូវការទឹកស្រោចស្រពផងដែរ។ ការវាយតម្លៃលើជម្រើសបីយ៉ាង បានផ្តល់លទ្ធផលដូចខាងក្រោម។
- លទ្ធផលវាយតម្លៃជម្រើសទី១បង្ហាញថា អាងស្ទឹងមានសក្តានុពលស្រោចស្រពស្រូវវស្សានិងប្រាំងបាន១០.៣៦៧ហិកតា។ ប៉ុន្តែបើសិនជាធារទឹកស្ទឹងប្រចាំឆ្នាំ ៣០% ត្រូវបានរក្សាទុកជា តម្រូវការទឹកក្នុងស្ទឹងសម្រាប់បរិស្ថាន ផ្ទៃដីនេះនឹងខ្វះទឹកស្រោចស្រព ៤,២លានម៣ ដោយភាគច្រើនខ្វះក្នុងខែមិថុនា (ខែមីនា ខ្វះប្រហែល ០,៩៥លានម៣)
- លទ្ធផលវាយតម្លៃជម្រើសទី២ បង្ហាញថា អាងមានសមត្ថភាពស្តុកទឹកបានតិច មិនអាចធានាបំពេញបន្ថែម ក្នុងពេលខ្វះខាតទឹកបានទេ។
- លទ្ធផលវាយតម្លៃជម្រើសទី៣ បង្ហាញថា ផ្ទៃដីស្រោចស្រពនឹងកើនដល់ ១៦.០៨៣ហិកតាក្នុងឆ្នាំ២០១៦។ ផ្អែកលើតួលេខកំណើននេះ គេអាចពិចារណាលើទិដ្ឋភាពពីរយ៉ាងដូចខាងក្រោម៖
  ១. បើសិនមិនគិតពីតម្រូវការទឹកក្នុងស្ទឹង សម្រាប់បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ ទឹកស្រោចស្រពនឹងត្រូវខ្វះ ២,៩៧លានម៣។
  ២. ដោយគិតបញ្ចូលតម្រូវការទឹកក្នុងស្ទឹងសម្រាប់បរិស្ថាន ស្មើនឹង ៣០% នៃធារទឹកប្រចាំឆ្នាំ និងតម្រូវការប្រើប្រាស់ផ្សេងៗទៀត ក្នុងអាងស្ទឹងនឹងមានកង្វះខាតទឹកស្រោចស្រព ៧,៨៩លានម៣ ភាគច្រើនខ្វះក្នុងខែមិថុនា (ក្នុងខែមីនា ខ្វះ ១,៣០លានម៣)។

---

១ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើឯកសារពិគ្រោះយោបល់មួយរបស់វិទ្យាស្ថាន CDRI ក្រោមប្រធានបទ *ការសិក្សាជលសាស្ត្រ ក្នុងកិច្ចគាំទ្រការគ្រប់គ្រងធារាសាស្ត្រ៖ ករណីសិក្សាអាងស្ទឹងជ្រៃបាក់ ខេត្តកំពង់ឆ្នាំង* ដោយអ្នកនិពន្ធ ចែម ផល្លា Philip Hirsch និង សុមេធ ប៉ារ៉ាឌី។

២ មកពីកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI។

៣ មកពីមជ្ឈមណ្ឌលស្រាវជ្រាវមេគង្គអូស្ត្រាលី ផ្នែកភូគពសាស្ត្រ នៃសាកលវិទ្យាល័យស៊ីដនី។

៤ មកពីដេប៉ាតឺម៉ង់ទេពកោសល្យជនបទ នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

- សរុបមក បើធារទឹកក្នុងស្ទឹងសម្រាប់បរិស្ថានមានអាទិភាពខ្ពស់ប៉ុនគ្នា ដូច្នេះផ្ទៃដីស្រោចស្រពគួរកម្រិតឲ្យនៅត្រឹម ១០.០០០ហិកតា។ ផ្ទុយទៅវិញ បើធារទឹកក្នុងស្ទឹងសម្រាប់បរិស្ថានមានអាទិភាពទាប ផ្ទៃដីស្រោចស្រពអាចពង្រីករហូតដល់ ១២.០០០ហិកតា។ ស្របពេលជាមួយគ្នានេះ ត្រូវអនុវត្តកម្មវិធីពង្រឹងសមត្ថភាពដំណើការ និងស្តារហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រឡើងវិញផងដែរ។

## ករណីសិក្សា៖ អាងស្ទឹងជ្រៃបាក់

អាងស្ទឹងជ្រៃបាក់ ជាផ្នែកមួយនៃអាងទន្លេសាប។ ទឹកស្ទឹងជ្រៃបាក់ហូរចូលទៅក្នុងទន្លេសាប។ មានប្រព័ន្ធធារាសាស្ត្រ ៧កន្លែង កំពុងដំណើការក្នុងអាងស្ទឹងនេះដែលមានផ្ទៃដីសរុប ១០.៣៦៧ហិកតា។ ប្រព័ន្ធធារាសាស្ត្រ ៤កន្លែង (ទី១ ដល់ ទី៤) នៅខ្សែទឹកខាងលើសម្រាប់ស្រោចស្រពបន្ថែមក្នុងរដូវវស្សា ចំណែកឯ ៣ទៀត (ទី៥ ដល់ ទី៧) សម្រាប់ស្រោចស្រពនៅរដូវវស្សាផង និងប្រាំងផង (រូបទី១)។

ការបង្កបង្កើនផលបានផ្លាស់ប្តូរយ៉ាងច្រើន ពីការធ្វើស្រែតែមួយដងក្នុងរដូវវស្សា មកធ្វើពីរឬបីដងក្នុងមួយឆ្នាំ។ កន្លងមកមានការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រជាបន្តបន្ទាប់ ដើម្បីបង្កើនសក្តានុពលស្រោចស្រព និងចៀសវាងការធ្វើស្រែពឹងលើទឹកភ្លៀងទាំងស្រុង។ ការអភិវឌ្ឍថ្មីៗបានបង្កើនផ្ទៃដីស្រូវប្រាំងដល់ ៧៤១ហិកតា ក្នុងប្រព័ន្ធធារាសាស្ត្រទី៥ ទី៦ និងទី៧ ក្នុងអាងស្ទឹងជ្រៃបាក់។ ប្រព័ន្ធធារាសាស្ត្រទី៧ ពឹងផ្អែកទាំងស្រុងលើធារទឹកក្នុងស្ទឹងនៅរដូវប្រាំង។ មានស្រែមួយចំនួនត្រូវខូចស្រូវដោយសារខ្វះទឹក។ ក្នុងពេលខ្វះទឹកម្តងៗ ជាពិសេសក្នុងខែមីនា កសិករតែងប្រជែងគ្នាបូមទឹកពីក្នុងស្ទឹង ដែលជួនកាលបង្កជាទំនាស់ពាក្យសំដីគ្នាទៀតផង (Chem & Someth 2011)។

## WEAP (Water Evaluation And Planning System)

ម៉ូដែល WEAP មានគុណសម្បត្តិ (១) អាចកំណត់បញ្ហាសម្រាប់គណនា និងដោះស្រាយ (២) បង្កើតប្រព័ន្ធបញ្ចូលទិន្នន័យ ដែលជាមូលដ្ឋាន សម្រាប់វាយតម្លៃលើសក្តានុពលទឹក និងតម្រូវការស្រោចស្រព ដោយផ្អែកលើទិន្នន័យឆ្នាំគោល[៥] (៣) បង្កើតនូវជម្រើសគ្រប់គ្រងផ្សេងៗ (៤) វាយតម្លៃលើជម្រើសនានា ដើម្បីសម្រេចយកជម្រើសគ្រប់គ្រងដែលសមស្របជាងគេ (Sieber & Purkey 2001, Yate *et al.* 2005)។

---

៥ ទិន្នន័យឆ្នាំគោល (២០០៧) ជាទិន្នន័យបានធ្វើបច្ចុប្បន្នភាពសម្រាប់ប្រើជាមូលដ្ឋាន ដើម្បីវាយតម្លៃជម្រើសគ្រប់គ្រងតម្រូវការទឹកនានា ក្នុងពេលអនាគត។ ទិន្នន័យឆ្នាំគោល តំណាងឲ្យដំណើការរូបវន្ត និងការប្រើប្រាស់ទឹកជាក់ស្តែងក្នុងអាងស្ទឹង។

រូបទី១ ផែនទីអាងស្ទឹងជ្រៃបាក់




ប្រភព៖ Chem *et al.* 2011

រូបទី២ ផែនទីវិភាគជលសាស្ត្រ



ប្រភព៖ Chem *et al.* 2011

ការសិក្សាបានប្រើម៉ូដែល WEAP ដើម្បីពិនិត្យពីជម្រើសផ្សេងៗ សម្រាប់ឆ្នាំ២០០៨ ដល់ ២០១៦ ដែលមានជាអាទិ៍៖ (១) ការពង្រឹងការងារគ្រប់គ្រង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ (២) លទ្ធភាពបន្ថែមអាងស្តុកទឹក និង (៣) កំណើនផ្ទៃដីស្រោចស្រព ៥%។ ការវាយតម្លៃជម្រើសទាំងនេះ ផ្អែកលើទិន្នន័យឆ្នាំ២០០៧ ជាគោល។ ចំណែកឯការសន្មតនានា ក្នុងការសិក្សាពីជម្រើសទាំងបីនេះ មានដូចជា៖

- ជម្រើសទី១សន្មតថា ទឹកស្រោចស្រពអាចសំចៃបាន ១% តាមរយៈការអនុវត្តកម្មវិធីពង្រឹងកិច្ចដំណើការ និងថែទាំប្រព័ន្ធធារាសាស្ត្របានល្អ។ ក្នុងជម្រើសនេះគេសន្មតថាគ្មានកំណើនផ្ទៃដីស្រោចស្រពទេ។
- ជម្រើសទី២ សន្មតថា មានកំណើនផ្ទៃដីស្រោចស្រព ៥% ក្នុងមួយឆ្នាំសម្រាប់ឆ្នាំ២០០៨ ដល់ ២០១៦។ បរិមាណទឹកស្តុកក្នុងអាង ត្រូវបានគិតបញ្ចូលទៅក្នុងការផ្គត់ផ្គង់ទឹកស្រោចស្រព។
- ជម្រើសទី៣ សន្មតថា មានកំណើនផ្ទៃដីស្រោចស្រព ៥% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០០៨ ដល់ ២០១៦។
- តម្រូវការទឹកក្នុងស្ទឹងសម្រាប់បរិស្ថាន គិតស្មើនឹង ៣០% នៃធារទឹកស្ទឹងសរុបប្រចាំឆ្នាំ។ ចំពោះឆ្នាំគោល (២០០៧) គេមិនបានបញ្ចូលតម្រូវការទឹកក្នុងស្ទឹងសម្រាប់បរិស្ថានទេ។

ជម្រើសទាំងបីនេះ ត្រូវបានវាយតម្លៃដោយពិចារណាពីសក្តានុពលធារទឹកស្ទឹង។

## លទ្ធផល

ធារទឹកក្នុងឆ្នាំ២០០៧ មាន ២៨៨,៩លានម៣ ហើយផ្ទៃដីស្រោចស្រពមាន ១០.៣៦៧ហិកតា។ ធារទឹកស្ទឹងតិចបំផុតក្នុងរដូវប្រាំងកើតឡើងក្នុងខែមីនា ដែលមាន ៤លានម៣ បន្ទាប់មកក្នុងខែកុម្ភៈ ដែលមាន ៥,៦លានម៣។ ធារទឹកតិចក្នុងរដូវវស្សាកើតឡើងក្នុងខែមិថុនា ដែលមាន ១២,៩១លានម៣ (Chem & Someth 2011) ។ លទ្ធផលវិភាគមានដូចខាងក្រោម៖

- ដោយមិនគិតបញ្ចូលធារទឹកក្នុងស្ទឹងសម្រាប់បរិស្ថាន ធារទឹកស្ទឹងជ្រៃបាក់អាចស្រោចស្រពបាន ១០.៣៦៧ហិកតា (ប្រាំង៧៩១ហិកតា)។
- ដោយរក្សាធារទឹកស្ទឹង ៣០% ជាតម្រូវការទឹកក្នុងស្ទឹងសម្រាប់បរិស្ថាន និងរក្សាផ្ទៃដីស្រោចស្រពឲ្យនៅដដែល (១០.៣៦៧ហិកតា) ទឹកស្រោចស្រពនឹងត្រូវខ្វះ ៤,២លានម៣ គឺនៅរដូវប្រាំងខ្វះ ០,៩៥លានម៣ ក្នុងខែមីនា និងរដូវវស្សាខ្វះ ៣,៣លានម៣ ក្នុងខែមិថុនា។
- បើផ្ទៃដីត្រូវស្រោចស្រពកើនឡើង ៥% ក្នុងមួយឆ្នាំពីឆ្នាំ២០០៨ ដល់ ២០១៦ ដូច្នេះវាត្រូវកើនដល់ ១៦.០៨៣ហិកតា។ សម្រាប់ផ្ទៃដីនេះ បើសិនគិតបញ្ចូលធារទឹកស្ទឹង ៣០% ទុកជា តម្រូវការទឹកក្នុងស្ទឹងសម្រាប់បរិស្ថានផង គេនឹងត្រូវខ្វះទឹកស្រោចស្រពប្រហែល ៧,៨៩លានម៣ គឺខែមីនា ខ្វះ ១,៣២លានម៣ និងខែមិថុនា ខ្វះ ៦,៥៧លានម៣ (រូបទី៣)។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

រូបទី៣ ទំនាក់ទំនងរវាងធារទឹក តម្រូវការទឹក និងកង្វះខាតទឹក ក្នុងជម្រើសមានកំណើនផ្ទៃដីស្រោចស្រព ៥%




- នៅអាងស្ទឹងជ្រៃបាក់ ពុំមានអាងស្តុកទឹកធំៗទេ។ អាងស្តុកទឹកក្នុងប្រព័ន្ធធារាសាស្ត្រទី៥ មានទំហំតូច មិនអាចធានាបំពេញបន្ថែមតម្រូវការទឹក ក្នុងពេលខ្វះខាតទឹកបានទេ។
- បើអ្នកធ្វើសេចក្តីសម្រេចចិត្ត ផ្តល់អាទិភាពខ្ពស់ដល់តម្រូវការធារទឹកក្នុងស្ទឹងសម្រាប់បរិស្ថានផង ផ្ទៃដីស្រោចស្រពក្នុងអាងស្ទឹងគួរកម្រិតឲ្យនៅត្រឹម ១០.០០០ហិកតា។ ប៉ុន្តែបើសិនមិនគិតពីតម្រូវការធារទឹកក្នុងស្ទឹង សម្រាប់បរិស្ថានផ្ទៃដីស្រោចស្រពអាចបង្កើនរហូតដល់ ១២.០០០ហិកតា ប៉ុន្តែក៏ត្រូវពង្រឹងសមត្ថភាពគ្រប់គ្រងប្រព័ន្ធ និងត្រូវស្តារហេដ្ឋារចនាសម្ព័ន្ធផងដែរ។

## ឯកសារយោង

Chem, P., P. Someth (2011), *Use of Hydrological Knowledge and Community Participation for Improving Irrigation Water Allocation,* CDRI Working Paper No. 49, March pp. 1-41

Chem, P., P. Hirsch, P. Someth (2011), *Hydrological Analysis in support of irrigation management: a case study of Stung Chrey Bak, Cambodia,* CDRI forth coming Working Paper (Phnom Penh: CDRI)

Sieber J., D. Purkey (2011) *WEAP – Water Evaluation and Planning System: User Guide.* (USA: Stockholm Environment Institute, US Centre, 11 Curtis Avenue, Somerville, MA)

Yates D., D. Purkey, J. Sieber, A. Huber-Lee, H. Gablbraith (2005) "WEAP21 – A Demand and Preference-Driven Water Planning Model, *International Water Resources Association,* December Vol. 30 (4), pp. 501–512